ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

-----

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

លេខ ០០៦.ប្រក.សហវ

រាជធានីភ្នំពេញ, ថ្ងៃទី ០៤ ខែមករា ឆ្នាំ២០០១

# ប្រកាសអន្តរក្រសួង

## ស្តីពី

## ការកំណត់ថ្លៃវត្ថុធាតុដើមថ្មសំភារៈសំណង់

~~~~~~~

### រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រីដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០២-នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-១០៩៩-០១ ចុះថ្ងៃទី ៣១ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញច្បាប់ស្តីពីការបង្កើតក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ នស-រកម-០១៩៦-០៥ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្របក ចុះថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៣៥ អនក្របក ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ១៩៩៩ ស្តីពីការរៀបចំ និង ការប្រព្រឹត្តិទៅរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល

### សំរេច

ប្រការ១ : ការធ្វើអាជីវកម្មជីកយកថ្មសំភារៈសំណង់ទាំងអស់ ត្រូវបង់ជូនរដ្ឋនូវថ្លៃវត្ថុធាតុដើម ។

ថ្មសំភារៈសំណង់រួមមាន : ថ្មសំណង់ ក្រួស ខ្សាច់ ដី ដីក្រហម ( ឡាតេរីត ) និង ដីឥដ្ឋ ។

ប្រការ២ : អាជីវករជាម្ចាស់ការដ្ឋាន ជាអ្នកទទួលខុសត្រូវបង់ថ្លៃវត្ថុធាតុដើមថ្មសំភារៈសំណង់ដែលជីកយក ឬលក់ចេញ ។

ប្រការ៣ : ថ្លៃវត្ថុធាតុដើមលើការធ្វើអាជីវកម្មជីកយកថ្មសំភារៈសំណង់ ត្រូវកំណត់តាមអត្រាដូចខាងក្រោម :

១- ០.៦ ដុល្លារអាមេរិក/ម៉ែត្រគូប ចំពោះថ្មសំណង់ដែលជាថ្មបំបែកគ្រប់ប្រភេទមានទំហំចាប់ពី ១ ស.ម x ២ ស.ម ឡើងទៅ
~~~~~~~

២- 0.៤ ដុល្លាអាមេរិក/ម៉ែត្រត្រីគុណ ចំពោះក្រួស ឬ ក្រួសក្រាវែត

៣- 0.២ ដុល្លាអាមេរិក/ ម៉ែត្រត្រីគុណ ចំពោះថ្មសំណង់ដែលជាថ្មបំបែកគ្រប់ប្រភេទមានទំហំតូចជាង
១ ស.ម x ២ ស.ម ខ្សាច់សំណង់ និង ដីក្រហម ( ឡាតេរីត ) ។

៤- 0.១ ដុល្លាអាមេរិក/ ម៉ែត្រត្រីគុណ ចំពោះផលិតផលសំរេចពីដីឥដ្ឋដែលរួមមាន ឥដ្ឋ ក្បឿង
និងផលិតផលពីដីឥដ្ឋផ្សេងៗទៀតលើកលែងតែផលិតផលកុលាលភាជន៍

៥- 0.១ ដុល្លាអាមេរិច/ម៉ែត្រត្រីគុណចំពោះអាចម៍ដីដែលជីកក្នុងបំណងពាណិជ្ជកម្មក្រៅពីការធ្វើអាជីវកម្ម
ដែលមានចែងក្នុងចំណុច ៤ ប្រការ ៣ ខាងលើ ។

ប្រការ៤ : ចំណូលពីថ្លៃវត្ថុធាតុដើមថ្មសំភារៈសំណង់ ត្រូវបានបែងចែក និងបង់ចូលថវិការដ្ឋ៨0ភាគរយ ថវិការខេត្ត-ក្រុង ២០ភាគរយ និងអនុញ្ញាតអោយក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដកវិញ ចំនួន១០ ភាគរយសំរាប់ចំណាយក្នុងការសិក្សាស្រាវជ្រាវភូគព្ភសាស្ត្រ និង ធនធានរ៉ែ ។

ប្រការ៥ : អាជីវករត្រូវបង់ថ្លៃវត្ថុធាតុដើមថ្មសំភារៈសំណង់នៅរតនាគារខេត្ត-ក្រុង ដែលខ្លួនបោះទីតាំងការដ្ឋានផលិតកម្ម និង អាជីវកម្មដោយផ្អែកតាមបញ្ជាចំណូល ( សាលាកប័ត្របង់ចំណូល ) របស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលខេត្ត-ក្រុង ។

ប្រការ៦ : ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលសហការជាមួយក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុធ្វើការកំណត់ និង គ្រោងខ្ទង់ចំណូលនេះនៅពេលធ្វើការពិភាក្សាថវិកាប្រចាំឆ្នាំនីមួយៗ ដោយកត់ត្រាដូចខាងក្រោម :

- ៨០ភាគរយនៃចំនួនដែលបានកំណត់ ត្រូវកត់ត្រាក្នុងគំរោងចំណូលរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលនៅថ្នាក់ខេត្ត-ក្រុង ( ថវិការដ្ឋ ) ត្រង់ជំពូក២០ ប្រការ 0៤ កថាខ័ណ្ឌ 0២ ( សម្បទានពីរ៉ែ ) ហើយខ្ទង់ចំណូលនេះនឹងត្រូវបែងចែកលំអិតនៅក្នុងសៀវភៅថវិការបស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលរបស់ខេត្ត-ក្រុងនីមួយៗ ។

- ១០ភាគរយនៃចំនួនដែលបានកំណត់ ត្រូវកត់ត្រាក្នុងគំរោងចំណាយរបស់ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលនៅថ្នាក់រដ្ឋបាលកណ្តាលត្រង់ជំពូក ១១ ប្រការ 0១ កថាខ័ណ្ឌ ១២ វាក្យខ័ណ្ឌ 0១ ( ការសិក្សា និង ពិសោធន៍ ) ។

- ២០ភាគរយនៃចំនួនដែលបានកំណត់ ត្រូវកត់ត្រាក្នុងគំរោងចំណូលរបស់សាលាខេត្ត-ក្រុង ( ថវិកាខេត្ត -ក្រុង ) ត្រង់ជំពូក ២០ ប្រការ 0៤ កថាខ័ណ្ឌ 0២ ( សម្បទានពីរ៉ែ ) ហើយខ្ទង់ចំណូលនេះនឹងត្រូវបែងចែកលំអិតនៅក្នុងសៀវភៅថវិការបស់សាលាខេត្ត-ក្រុងនីមួយៗ ។

ប្រការ៧ : ផ្អែកលើមូលដ្ឋានគំរោងចំណូលដែលបានកត់ត្រាក្នុងសៀវភៅថវិការបស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល គណៈកម្មាធិការចំរុះដែលរួមមាន : តំណាងក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលជាប្រធាន តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង អាជ្ញាធរដែនដីជាសមាជិក ត្រូវចុះទៅធ្វើការត្រួតពិនិត្យសកម្មភាពផលិតកម្មអាជីវកម្មតាមការដ្ឋាននីមួយៗ ដើម្បីគណនានូវចំនួនទឹកប្រាក់ដែលអាជីវករត្រូវបង់ពិតប្រាកដ ។

ប្រការ៨ : នៅសប្តាហ៍ទី១រៀងរាល់ខែបន្ទាប់ មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលដោយផ្អែកលើចំនួនទឹកប្រាក់ដែលត្រូវបង់ពិតប្រាកដ ត្រូវចេញបញ្ជីចំណូលឱ្យទៅអាជីវករដោយចែកចេញជាពីរច្បាប់ : មួយច្បាប់កត់ត្រានូវចំនួនទឹកប្រាក់៨0ភាគរយសំរាប់បង់ចូលថវិការដ្ឋ និងមួយច្បាប់ទៀត២០ភាគរយបង់ចូលថវិកាខេត្ត-ក្រុង ។

ប្រការ៩ : មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវធ្វើរបាយការណ៍ស្តីពីសភាពការណ៍អនុវត្តកាតព្វកិច្ចចំណូលប្រចាំខែជូន ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល និង ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ (នាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋ) ដោយថតចំលងភ្ជាប់មកជាមួយនូវសាលាកប័ត្របង់ចំណូលទាំងអស់ដែលអនុវត្តបាន ។

ប្រការ១០ : ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលត្រូវធ្វើអាណត្តិបើកប្រាក់សំរាប់ចំណាយលើការសិក្សាស្រាវជ្រាវ ភូគព្ភសាស្ត្រ និង ធនធានរ៉ែនូវទឹកប្រាក់ដែលមានសមាមាត្រសមមូលទៅនឹងចំនួនទឹកប្រាក់សរុប នៃសាលាកប័ត្របង់ចំណូលរបស់មន្ទីរឧស្សាហកម្ម រ៉ែ និង ថាមពល ហើយសាលាកប័ត្របង់ចំណូលនេះ ត្រូវភ្ជាប់តាមជាមួយនូវលិខិតយុទ្ធការនៅពេលមកចុះទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ ។

ប្រការ១១ : អាជីវករដែលជាប់កាតព្វកិច្ចបង់ថ្លៃវត្ថុធាតុដើមថ្មសំភារៈសំណង់ ត្រូវបង់ពន្ធផ្សេងៗទៀតតាមច្បាប់ សារពើពន្ធជាធរមាន ។

ប្រការ១២ : កាតព្វកិច្ចហិរញ្ញវត្ថុដែលមានចែងក្នុងកិច្ចព្រមព្រៀងស្តីពីការធ្វើអាជីវកម្មវត្ថុធាតុដើមថ្មសំភារៈសំណង់រវាង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល និងអាជីវករដែលមានពីមុន ហើយផ្ទុយនឹងប្រកាសនេះត្រូវទុក ជានិរាករណ៍ ។

ប្រការ១៣ : អង្គភាពចំណុះក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ និង ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពលដែលមានការពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តតាមប្រកាសនេះ ។

ប្រការ១៤ : ប្រកាសនេះ មានប្រសិទ្ធភាព និងចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

| ទេសរដ្ឋមន្ត្រី | រដ្ឋមន្ត្រី |
|---|---|
| រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ | ក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល |
| គាត ឈន់ | ស៊ុយ សែម |

ចំលងជូន :
- ខុទ្ទកាល័យព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង រដ្ឋលេខាធិការដ្ឋាន
- គ្រប់ខេត្ត-ក្រុង
  ដើម្បីជូនជ្រាប ។
- ដូចប្រការ ១៣
  ដើម្បីអនុវត្ត ។
- កាលប្បវត្តិ-ឯកសារ